# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧..សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការធ្វើវិសោធនា

## លើសេចក្តីព្រាងសៀវភៅ ស ការពារជាតិ ២០០៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារៈកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- បានឃើញសេចក្តីសំរេចលេខ ០២៥/០៥ សសរ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៤ របស់ក្រសួងការពារជាតិ ស្តីពីការបង្កើតក្រុមការងារសៀវភៅ ស ការពារជាតិ ២០០៤
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

# ស ម្រេ ច

**ប្រការ ១ :**

បង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការធ្វើវិវេចនាលើសេចក្តីព្រាងសៀវភៅ ស ការពារជាតិ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- សហរដ្ឋមន្ត្រីក្រសួងការពារជាតិ | ជាសហប្រធាន |
| ២- អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ | ជាអនុប្រធាន |
| ៣- ប្រធានក្រុមការងារអនុវត្តគោលការណ៍សៀវភៅ ស ការពារជាតិ ២០០៥ | ជាអនុប្រធាន |
| ៤- ប្រធានក្រុមការងារសៀវភៅ ស ការពារជាតិ ២០០៥ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៥- មេបញ្ជាការកងទ័ពជើងគោក | ជាសមាជិក |
| ៦- មេបញ្ជាការកងទ័ពជើងទឹក | ជាសមាជិក |
| ៧- មេបញ្ជាការកងទ័ពជើងអាកាស | ជាសមាជិក |
| ៨- មេបញ្ជាការកងរាជអាវុធហត្ថ | ជាសមាជិក |
| ៩- អគ្គលេខាធិការក្រសួងការពារជាតិ | ជាសមាជិក |
| ១០- អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ | ជាសមាជិក |
| ១១- អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា | ជាសមាជិក |
| ១២- អគ្គនាយក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | ជាសមាជិក |
| ១៣- នាយកខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន | ជាសមាជិក |
| ១៤- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ១៥- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ១៦- តំណាងក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៧- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ១៨- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ជាសមាជិក |
| ១៩- តំណាងក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | ជាសមាជិក |
| ២០- តំណាងក្រសួងបរិស្ថាន | ជាសមាជិក |
| ២១- តំណាងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី | ជាសមាជិក |
| ២២- នាយក នាយកដ្ឋានទាក់ទងអន្តរជាតិ ក្រសួងការពារជាតិ | ជាសមាជិក |

**ប្រការ ២ :**

គណៈកម្មការនេះមានភារកិច្ចពិនិត្យសើរើ និងសិក្សាលើសេចក្តីព្រាងឯកសារសៀវភៅ ស ការពារជាតិ ដែលបានតាក់តែងដោយក្រុមការងារសៀវភៅ ស ការពារជាតិ ២០០៥ ព្រមទាំងធ្វើការកែលំអឯកសារនេះឱ្យមាន

លក្ខណៈសមស្របទៅនឹងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើមាគ៌ានយោបាយសន្តិសុខជាតិរបស់រាជរដ្ឋាភិបាលជាមូលដ្ឋាននិងឆ្លើយតបទៅនឹងផែនការអភិវឌ្ឍន៍កងកម្លាំងប្រដាប់អាវុធ នៃកងយោធពលខេមរភូមិន្ទ ។

**ប្រការ ៣ ៖**

សមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំការងារតាមការកោះអញ្ជើញរបស់សហប្រធាន ។

**ប្រការ ៤ ៖**

បន្ទាប់ពីមានការឯកភាពទៅលើចំណុចទាំងអស់ នៃសេចក្តីព្រាងឯកសារសៀវភៅ ស នេះហើយ គណៈកម្មការត្រូវស្នើសុំសច្ចាប័នពីរាជរដ្ឋាភិបាល មុនពេលដែលឯកសារនេះត្រូវចេញផ្សាយជាផ្លូវការ ។

**ប្រការ ៥ ៖**

គណៈកម្មការនេះមានសិទ្ធិប្រើត្រារបស់ក្រសួងការពារជាតិ សំរាប់ដំណើរការអនុវត្តការងាររបស់ខ្លួន ។

**ប្រការ ៦ ៖**

ក្រោយពីបានទទួលសេចក្តីសំរេចនេះ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធត្រូវប្រញាប់ផ្ញើឈ្មោះតំណាង ០១រូប ដែលមានឋានៈចាប់ពី អនុរដ្ឋលេខាធិការឡើងទៅ (ឈ្មោះ ឋានៈ មុខតំណែង លេខទូរស័ព្ទ ) ឱ្យទៅអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ ដើម្បីងាយស្រួលក្នុងការអញ្ជើញចូលរួមប្រជុំ និងទំនាក់ទំនងកិច្ចការនេះ ។

**ប្រការ ៧ ៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងពាក់ព័ន្ធ ព្រមទាំងសមាសភាពដែលមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៥*

ហ៊ុន សែន

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
  *(ដើម្បីជូនជ្រាប)*
- *ដូចប្រការ ៧*
  *(ដើម្បីអនុវត្ត)*
- *ឯកសារ_កាលប្បវត្តិ*